

# ដំណាំល្ហុង

## ១- ការរៀបចំដីដាំល្ហុង:

- យើងត្រូវភ្ជួរហាលដីទុកចោលចំនួន ១ខែទៅ ១ ខែ កន្លះសិន ដើម្បីអោយងាប់សត្វល្អិតនិងស្មៅ រលួយបានល្អ។ យើងត្រូវ ភ្ជួរដីមួយលើកទៀត នៅពេលដែលជិតដាំកូនល្ហុង។
- យើងត្រូវទាញខ្សែអោយត្រង់ ដើម្បីងាយស្រួលក្នុងការដាំដំណាំផ្សេងទៀត ក្រោមដើមល្ហុង។
- ចន្លោះពីដើមមួយទៅដើមមួយទៀត ប្រវែង ៣ ម៉ែត្រ។
- យើងត្រូវដោតបង្គោលចំណាំរណ្តៅដែលយើងវាស់រួចហើយ យកជីវែគ ចំនួន៥00cc លាយទឹក ២0L មកបាញ់ឲ្យជោគ ចំបង្គោលរណ្តៅទំហំ២កឹត ៤ជ្រុង រួចទុករយៈពេល ៧ថ្ងៃ ទើបយើងកាប់រណ្តៅ។ មុនបាញ់ជី ត្រូវស្រោចទឹកចំកន្លែងរណ្តៅអោយជោគសិន ទើបបាញ់ជីវែគ ដើម្បីអោយ ជីជ្រាបចូលទៅក្នុងដីបានល្អ វាធ្វើឲ្យដីផុសល្អសំបូរជីជាតិ និងសត្វជន្លេន។




## ២- ការដាំកូនល្ហុង:

- កាប់រណ្តៅដែលយើងស្រោចជីហើយ ទំហំ ២តឹក ជំរៅ២តឹក កាប់បំផុសដីឲ្យម៉ត់ ដោយលាយជាមួយជីអាចម៍គោពុកល្អ។
- កូនល្ហុងអាយុពី១ខែកន្លះ ទៅ២ ខែមានប្រវែងមួយចង្អាមដៃ។ យើងត្រូវស្រោចទឹកឲ្យជោគមុនយកទៅដាំ។
- យកថង់ចេញ ដោយកុំអោយបែកអាចម៍ដី និងដាច់ឫសល្ហុងបណ្តាលឲ្យកូនល្ហុងងាប់បាន។
- កប់កូនល្ហុងអោយលិចដីកន្តោង រួចយកអាចម៍ដីមកពូនសង្កត់អោយណែន បន្ទាប់មកស្រោចទឹក អោយជោគ។
- ត្រូវស្រោចទឹកជារៀងថ្ងៃ នៅពេលល្ងាចអោយជោគល្មម។

## ៣- ការថែទាំដើមល្ហុង:

- ក្រោយដាំរួចយើងត្រូវបាញ់ថ្នាំការពារសត្វល្អិតណ៉ាតូ" ក្នុងកំរិតប្រើ ៣0cc លាយជាមួយទឹក ១៦L បាញ់ទៅលើកូនល្ហុង ដើម្បីការពារកុំឲ្យសត្វល្អិតស៊ី ឬកាត់ដើមល្ហុងចោល រៀងរាល់៥ទៅ៧ថ្ងៃម្តងរហូតដល់កូនល្ហុងមានដើមប៉ុនចង្កេះ។
- ដាំបានរយៈពេល ១ខែ បើមានស្មៅដុះជុំវិញគល់ល្ហុង យើងត្រូវដកវាចេញឲ្យអស់ ពីព្រោះបើទុកវាធ្វើឲ្យដើមល្ហុងមានការលូតលាស់យឺត។
- ក្រោយពេលសំអាតស្មៅរួចហើយយើងត្រូវជ្រុំនិងពូនគល់ល្ហុងម្តង។ រយៈពេល ២ខែបន្ទាប់ពីដាំ ដើមល្ហុងមានកំពស់ត្រឹមជង្គង់ យើងត្រូវធ្វើស្មៅ តាមគល់ល្ហុង និងជ្រុំពូនគល់ម្តងទៀតជាការស្រេច ព្រោះល្ហុងជិតចេញផ្កាហើយ។
- បន្ទាប់ពីជ្រុំពូនគល់លើកទី២រួចហើយ យើងត្រូវ ស្រោចទឹកតាមគល់ល្ហុងអោយជោគសិនទើប យើងយកជីវែគមកបាញ់ម្តងទៀត។បាញ់ម្តងនេះគឺធ្វើឲ្យដើមល្ហុងធំរឹងមាំ ហើយជំនួយ

